**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២២៦ ព.ណ.គ.ក.គ.ប.ប.ប្រក

# ប្រកាស
# ស្តីពី
# បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេត ក្រោមច្បាប់ស្តីពីការប្រកួតប្រជែង

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១._ គោលបំណង

ប្រកាសនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេត ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីកំណត់ថាការព្រមព្រៀងឬសកម្មភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង តាមរយៈការត្រួតពិនិត្យនិងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។

### ប្រការ២._ វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការត្រួតពិនិត្យនិងការស៊ើបអង្កេត ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ដែលត្រូវអនុវត្តដោយមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «**ក.ប.ប.**»។

### ប្រការ៣._ និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

១. **អគ្គនាយកដ្ឋាន ក.ប.ប.** សំដៅដល់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ។

២. **អ្នកដាក់ពាក្យបណ្តឹង** សំដៅដល់បុគ្គលទាំងឡាយណា ដែលបានដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដូចមានចែងនៅក្នុងប្រការ៤ និងប្រការ៥នៃប្រកាសនេះ។

៣. **មន្ត្រីស៊ើបអង្កេត** សំដៅដល់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ដែលត្រូវបានចាត់តាំងឱ្យស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

៤. **បុគ្គលស្ថិតក្រោមការស៊ើបអង្កេត** សំដៅដល់បុគ្គលទាំងឡាយណា ដែលអាចបំពានច្បាប់ស្តីពីការប្រកួតប្រជែង។

៥. **សិទ្ធិ និងកាតព្វកិច្ច** សំដៅដល់សិទ្ធិនិងកាតព្វកិច្ចរបស់មន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងជំពូកទី៤នៃច្បាប់ស្តីពីការប្រកួតប្រជែង និងបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត ដូចមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

៦. **ទីកន្លែងឆែកឆេរ** សំដៅដល់ទីកន្លែងធ្វើការ និងយានយន្តផ្សេងៗ ដោយមិនរួមបញ្ចូលនូវទីកន្លែងលំនៅដ្ឋានឬទីសំណាក់ លើកលែងតែក្នុងករណីដែលទីកន្លែងលំនៅដ្ឋានឬទីសំណាក់នោះត្រូវបានប្រើប្រាស់ ដោយមានទំនាក់ទំនងនឹងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ឬឯកសារឬភស្តុតាង ដែលពាក់ព័ន្ធនឹងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនោះត្រូវបានរក្សាទុកនៅទីកន្លែងលំនៅដ្ឋានឬទីសំណាក់នោះ។

៧. **ដីកាអនុញ្ញាតឱ្យឆែកឆេរ** សំដៅដល់លិខិតអនុញ្ញាតចេញដោយប្រធានសាលាដំបូងមានសមត្ថកិច្ចដែនដីតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ដើម្បីអនុញ្ញាតឱ្យមន្ត្រីស៊ើបអង្កេតចូលទៅក្នុងទីកន្លែងឆែកឆេរជាក់លាក់ណាមួយ ដូចបានកំណត់ក្នុងលិខិតអនុញ្ញាតនោះ ដើម្បីធ្វើការឆែកឆេរលើបុគ្គល ព័ត៌មាន

ទិន្នន័យឬឯកសារផ្សេងៗ នៅក្នុងបរិវេណនៃទីកន្លែងឆែកឆេរនោះ ឬធ្វើនូវសកម្មភាពណាមួយឬទាំងអស់ ដូចមានចែងក្នុងប្រកាសនេះ ដោយអនុលោមតាមមាត្រា១១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី២

## បណ្តឹង និងការត្រួតពិនិត្យបឋម

### ប្រការ៤.- ការដាក់ពាក្យបណ្តឹងដោយបុគ្គល

បុគ្គលណាមួយ ទោះមានឬគ្មានផលប្រយោជន៍ពាក់ព័ន្ធនឹងការព្រមព្រៀងឬសកម្មភាពដែលអាចរាំងរឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ដែលបានដឹង ឬសង្ស័យដោយមានមូលហេតុសមស្របណាមួយលើការបំពានច្បាប់ស្តីពីការប្រកួតប្រជែង អាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរមក **គ.ប.ក.** ដោយផ្ទាល់ឬមធ្យោបាយផ្សេងទៀត។

ពាក្យបណ្តឹងដែលធ្វើឡើងដោយបុគ្គល ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់នូវព័ត៌មានពាក់ព័ន្ធដូចខាងក្រោម៖

ក. ព័ត៌មានរបស់អ្នកដាក់ពាក្យបណ្តឹង និង/ឬអ្នកតំណាងស្របច្បាប់

ខ. ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធ

គ. សេចក្តីសង្ខេបអំពីការព្រមព្រៀងឬសកម្មភាពដែលអាចរាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង និង

ឃ. ព័ត៌មាននិងឯកសារពាក់ព័ន្ធផ្សេងៗ។

អគ្គនាយកដ្ឋាន **ក.ប.ប.** ជាលេខាធិការដ្ឋានរបស់ **គ.ប.ក.** ក្នុងការទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងការប្រកួតប្រជែង។

### ប្រការ៥.- ការដាក់ពាក្យបណ្តឹងដោយក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ច

ក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ច ដែលបានដឹងឬមានការសង្ស័យដោយមូលហេតុសមស្របណាមួយលើការបំពានបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រកួតប្រជែង អាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរមក **គ.ប.ក.** ដោយផ្ទាល់ឬមធ្យោបាយផ្សេងទៀត។

ពាក្យបណ្តឹងដែលធ្វើឡើងដោយក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ច ត្រូវកំណត់នូវព័ត៌មានពាក់ព័ន្ធដូចខាងក្រោម៖

ក. ព័ត៌មានរបស់អ្នកដាក់ពាក្យបណ្តឹង និង/ឬអ្នកតំណាងស្របច្បាប់

ខ. ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធ

គ. សេចក្តីសង្ខេបអំពីការព្រមព្រៀងឬសកម្មភាពដែលអាចរាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

ឃ. ព័ត៌មាននិងឯកសារពាក់ព័ន្ធផ្សេងៗ និង

ង. សេចក្តីបញ្ជាក់ ឬកំណត់ហេតុវាយតម្លៃលើការព្រមព្រៀងឬសកម្មភាពដែលអាចរាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

អគ្គនាយកដ្ឋាន **ក.ប.ប.** ជាលេខាធិការដ្ឋានរបស់ **គ.ប.ក.** ក្នុងការទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងការប្រកួតប្រជែង។

## ប្រការ៦._ ការផ្ដួចផ្ដើមបណ្ដឹងដោយ គ.ប.ក.

ដោយអនុលោមតាមមាត្រា១៦នៃច្បាប់ស្ដីពីការប្រកួតប្រជែង **គ.ប.ក.** អាចផ្ដួចផ្ដើមបណ្ដឹងនិងដោះស្រាយដោយខ្លួនឯងឬតាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សររបស់អគ្គនាយកដ្ឋាន **ក.ប.ប.** បន្ទាប់ពីបានដឹងឬមានការសង្ស័យដោយមូលហេតុសមស្របណាមួយពីការកើតឡើងនូវការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងណាមួយ។

ការស្នើសុំជាលាយលក្ខណ៍អក្សរដោយអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវកំណត់នូវព័ត៌មានពាក់ព័ន្ធដូចខាងក្រោម៖

ក. ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធ

ខ. សេចក្ដីសង្ខេបអំពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

គ. ព័ត៌មាននិងឯកសារពាក់ព័ន្ធផ្សេងៗ និង

ឃ. សេចក្ដីបញ្ជាក់ ឬកំណត់ហេតុវាយតម្លៃលើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

## ប្រការ៧._ ការចាប់ផ្ដើមការត្រួតពិនិត្យបឋម

បន្ទាប់ពីទទួលបានពាក្យបណ្ដឹងដូចមានចែងក្នុងប្រការ៤ និងប្រការ៥នៃប្រកាសនេះ អគ្គនាយកដ្ឋាន **ក.ប.ប.** ដែលជាលេខាធិការដ្ឋានរបស់ **គ.ប.ក.** ក្នុងការទទួលពាក្យបណ្ដឹង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការដាក់ពាក្យបណ្ដឹងជូន **គ.ប.ក.**។ បន្ទាប់ពីមានការសម្រេចពី **គ.ប.ក.** អគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវចាត់តាំងមន្ត្រីស៊ើបអង្កេតក្នុងរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនោះ ដើម្បីចាប់ផ្ដើមធ្វើការត្រួតពិនិត្យបឋម។

ក្នុងករណីពាក្យបណ្ដឹងគឺជាការផ្ដួចផ្ដើមរបស់ **គ.ប.ក.** ខ្លួនឯង ដូចមានចែងក្នុងប្រការ៦នៃប្រកាសនេះ អគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវចាត់តាំងមន្ត្រីស៊ើបអង្កេតក្នុងរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្ដើមបណ្ដឹង ដើម្បីចាប់ផ្ដើមធ្វើការត្រួតពិនិត្យបឋម។

ក្នុងករណីពាក្យបណ្ដឹងគឺជាការផ្ដួចផ្ដើមរបស់ **គ.ប.ក.** តាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សររបស់អគ្គនាយកដ្ឋាន **ក.ប.ប.** ដូចមានចែងក្នុងប្រការ៦នៃប្រកាសនេះ អគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវចាត់តាំងមន្ត្រីស៊ើបអង្កេតក្នុងរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីមានការសម្រេចពី **គ.ប.ក.** ដើម្បីចាប់ផ្ដើមធ្វើការត្រួតពិនិត្យបឋម។

ការត្រួតពិនិត្យបឋម ត្រូវបញ្ចប់ដោយមន្ត្រីស៊ើបអង្កេតក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតចាត់តាំង ហើយអាចពន្យារពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការបន្ថែមទៀត។

## ប្រការ៨._ កំឡុងពេលនៃការត្រួតពិនិត្យបឋម

ក្នុងកំឡុងពេលនៃការត្រួតពិនិត្យបឋម មន្ត្រីស៊ើបអង្កេតត្រូវកំណត់ឱ្យបានថាតើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនោះ មានមូលហេតុសមស្របសម្រាប់ការសង្ស័យឬអត់ដោយពិចារណាទៅលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

ក. យុត្តាធិការ និងសមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេត និង/ឬ **គ.ប.ក.** ទៅលើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

ខ. ផលប្រយោជន៍ជាក់លាក់ណាមួយនៃអ្នកដាក់ពាក្យបណ្ដឹង

គ. ភាពមិនអនុលោមណាមួយតាមប្រការ៤ និងប្រការ៥នៃប្រកាសនេះ

ឃ. បទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាក់លាក់ណាមួយ ដែលត្រូវបានបំពាន និង

ង. មូលហេតុដែលមិនអនុញ្ញាតឱ្យបន្តនីតិវិធីនៃការស៊ើបអង្កេត រួមមាន៖

- កម្មវត្ថុនៃបណ្ដឹងមិនបានបង្ហាញអំពីការបំពានណាមួយ នៃច្បាប់ស្ដីពីការប្រកួតប្រជែង
- កម្មវត្ថុនៃបណ្ដឹងមិនបានបង្ហាញអំពីផលប៉ះពាល់ណាមួយដល់ការប្រកួតប្រជែង នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា
- អង្គហេតុ ភស្តុតាង និងឯកសារពាក់ព័ន្ធផ្សេងៗដែលបានផ្ដល់ឱ្យ ឬរកឃើញក្នុងកំឡុងពេលនៃការត្រួតពិនិត្យបឋម មិនបានបង្កើតឱ្យមាននូវមូលហេតុសមស្រប និងមានភាពស៊ីសង្វាក់គ្នាដើម្បីបន្តការស៊ើបអង្កេត
- ការត្រួតពិនិត្យបឋមអាចប្រមូលផ្ដុំនូវអង្គហេតុ ភស្តុតាង និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបញ្ជាក់ថាគ្មានការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង
- ការត្រួតពិនិត្យបឋមបានបង្ហាញថាការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ស្ថិតក្នុងករណីលើកលែងដូចមានចែងក្នុងមាត្រា១២នៃច្បាប់ស្ដីពីការប្រកួតប្រជែង និង
- ហេតុផលផ្សេងៗទៀតដែលមិនអនុញ្ញាតឱ្យបន្តនីតិវិធីស៊ើបអង្កេតលើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

ដើម្បីបញ្ជាក់អំពីការកំណត់ខាងលើ មន្ត្រីស៊ើបអង្កេតមានសិទ្ធិសាកសួរ និងស្នើសុំឱ្យមានការបកស្រាយបំភ្លឺពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ដែលមានភាពចាំបាច់ និងពាក់ព័ន្ធដល់ការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

## ប្រការ៩.- ការបញ្ចប់ការត្រួតពិនិត្យបឋម

នៅក្នុងដំណាក់កាលនៃការត្រួតពិនិត្យបឋម មន្ត្រីស៊ើបអង្កេតមានសិទ្ធិសម្រេច ដូចខាងក្រោម៖

ក. បិទការត្រួតពិនិត្យបឋម ប្រសិនបើគ្មានមូលហេតុនិងភស្តុតាងត្រឹមត្រូវ និងគ្រប់គ្រាន់ពាក់ព័ន្ធនឹងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

ខ. បើកការស៊ើបអង្កេត ប្រសិនបើមានមូលហេតុនិងភស្តុតាងត្រឹមត្រូវ និងគ្រប់គ្រាន់ពាក់ព័ន្ធនឹងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

គ. រៀបចំបន្តនីតិវិធីទៅព្រះរាជអាជ្ញា ប្រសិនបើមន្ត្រីស៊ើបអង្កេតមានមូលហេតុនិងភស្តុតាងត្រឹមត្រូវ និងគ្រប់គ្រាន់ពាក់ព័ន្ធនឹងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនោះ អាចបំពានមាត្រា៧នៃច្បាប់ស្ដីពីការប្រកួតប្រជែង និង/ឬ

ឃ. ស្នើសុំឱ្យ **គ.ប.ក.** ចេញវិធានការផ្អាកជាបណ្ដោះអាសន្ន ដូចមានចែងក្នុងមាត្រា២៧នៃច្បាប់ស្ដីពីការប្រកួតប្រជែង ប្រសិនបើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនោះអាចបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់ស្ដីពីការប្រកួតប្រជែង។

បន្ទាប់ពីបញ្ចប់ការត្រួតពិនិត្យបឋម មន្ត្រីស៊ើបអង្កេតត្រូវផ្ដល់នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយមានភ្ជាប់ជាមួយនូវភស្តុតាងនិងឯកសារពាក់ព័ន្ធផ្សេងៗជូន **គ.ប.ក.** សម្រាប់ទុកជាព័ត៌មាន ពិនិត្យនិងចេញសេចក្ដី

សម្រេច។ របាយការណ៍នេះត្រូវហៅថា «**របាយការណ៍ស្តីពីការត្រួតពិនិត្យបឋម**» ដែលទម្រង់នៃរបាយការណ៍ស្តីពីការត្រួតពិនិត្យបឋមមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

## ជំពូកទី៣
## នីតិវិធី និងសិទ្ធិក្នុងការស៊ើបអង្កេត

### ប្រការ១០.- ការបង្កើតគណៈកម្មការលើករណីប្រកួតប្រជែង

បន្ទាប់ពីការចេញសេចក្តីសម្រេចរបស់ **គ.ប.ក.** លើការចាប់ផ្តើមការស៊ើបអង្កេត **គ.ប.ក.** ត្រូវរៀបចំបង្កើតគណៈកម្មការលើករណីប្រកួតប្រជែង ដើម្បីពិនិត្យនិងស្រាវជ្រាវលើករណីប្រកួតប្រជែងតាមរយៈការពិភាក្សា ការសាកសួរ និងការស្តាប់របាយការណ៍ស្តីពីការត្រួតពិនិត្យបឋម ដែលធ្វើឡើងដោយមន្ត្រីស៊ើបអង្កេត និងសេចក្តីបញ្ជាក់ការការពារខ្លួន ដែលធ្វើឡើងដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ប្រសិនបើមាន។

គណៈកម្មការលើករណីប្រកួតប្រជែង ដែលបង្កើតឡើងដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ អាចតម្រូវឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធចាំបាច់នានាសម្រាប់ដំណើរការស៊ើបអង្កេតលើករណីប្រកួតប្រជែង។

ទីកន្លែងនិងកាលបរិច្ឆេទនៃការពិភាក្សា ការសាកសួរ និងការស្តាប់ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើត្រូវកំណត់ដោយគណៈកម្មការលើករណីប្រកួតប្រជែង និងត្រូវធ្វើឡើងបន្ទាប់ពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានដាក់សេចក្តីបញ្ជាក់ការការពារខ្លួនទៅមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ប្រសិនបើមាន ឬបន្ទាប់ពីការផុតសុពលភាពនៃការតម្រូវឱ្យផ្តល់សេចក្តីបញ្ជាក់ការការពារខ្លួនទៅមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.**។

គណៈកម្មការលើករណីប្រកួតប្រជែង អាចកោះហៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធដើម្បីចូលរួមក្នុងការពិភាក្សា ការសាកសួរ និងការស្តាប់ ដោយត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធយ៉ាងតិចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធខកខានក្នុងការចូលរួមការពិភាក្សា ការសាកសួរ និងការស្តាប់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធត្រូវផ្តល់នូវហេតុផលសមស្របចំពោះការខកខាននេះ។

ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធខកខានក្នុងការចូលរួមការពិភាក្សា ការសាកសួរ និងការស្តាប់ ចំនួន២(ពីរ)លើកជាប់គ្នា ទោះបីមានឬគ្មានមូលហេតុសមស្របណាមួយក៏ដោយ គណៈកម្មការលើករណីប្រកួតប្រជែងអាចបន្តនីតិវិធីបាន ដោយមិនតម្រូវឱ្យមានវត្តមានបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ឬអ្នកតំណាងស្របច្បាប់។

### ប្រការ១១.- ការចាប់ផ្តើមការស៊ើបអង្កេត

បន្ទាប់ពីការចេញសេចក្តីសម្រេចរបស់ **គ.ប.ក.** លើការចាប់ផ្តើមការស៊ើបអង្កេត គណៈកម្មការលើករណីប្រកួតប្រជែង ត្រូវចេញលិខិតចាត់តាំងមន្ត្រីស៊ើបអង្កេតទទួលបន្ទុកលើការស៊ើបអង្កេត។

បន្ទាប់ពីទទួលបានការចាត់តាំង មន្ត្រីស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតភ្លាមៗ លើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

មន្ត្រីស៊ើបអង្កេតត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរលើករណីដែលត្រូវធ្វើការស៊ើបអង្កេតទៅអ្នកដាក់ពាក្យបណ្តឹង និងបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ។ លិខិតជូនដំណឹងជាលាយលក្ខណ៍

អក្សរនេះ ត្រូវហៅថា «**លិខិតជូនដំណឹងស្តីពីការចាប់ផ្តើមការស៊ើបអង្កេត**» ដែលទម្រង់នៃលិខិតជូនដំណឹងនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

លិខិតជូនដំណឹងស្តីពីការចាប់ផ្តើមការស៊ើបអង្កេតត្រូវ៖

ក. បញ្ជាក់ឱ្យបានច្បាស់អំពីកាលបរិច្ឆេទផុតកំណត់ក្នុងការដាក់សេចក្តីបញ្ជាក់ការការពារខ្លួនរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ជូនមន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងប្រការ២៧នៃប្រកាសនេះ និង

ខ. ភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីការត្រួតពិនិត្យបឋម។

## ប្រការ១២._ សិទ្ធិក្នុងការស៊ើបអង្កេត

មន្ត្រីស៊ើបអង្កេតមានសិទ្ធិដូចខាងក្រោម៖

ក. ធ្វើការឆែកឆេរដល់ទីកន្លែងណាមួយដោយមាន ឬគ្មានការយល់ព្រមពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធប្រសិនបើចាំបាច់ ដូចមានចែងក្នុងប្រការ១៨ និងប្រការ១៩នៃប្រកាសនេះ។

ខ. សាកសួរបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានបន្ថែមតាមរយៈការចេញលិខិតកោះហៅជាមុនយ៉ាងតិចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ទៅឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ១៧នៃប្រកាសនេះ។

គ. បង្គាប់ឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ផ្តល់និងរៀបចំឯកសារនិងព័ត៌មានពាក់ព័ន្ធផ្សេងៗ ស្របតាមប្រការ១៦នៃប្រកាសនេះ។

ឃ. ស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ២១នៃប្រកាសនេះ។

## ប្រការ១៣._ ជម្រើសនៃសមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេត

ដោយអនុលោមតាមមាត្រា១៧ និងមាត្រា១៨នៃច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ មន្ត្រីស៊ើបអង្កេតអាចទទួលបាននូវជម្រើសនៃសមត្ថកិច្ច ដែលមានសមត្ថកិច្ចជាមន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងប្រការ១២នៃប្រកាសនេះ ឬជានគរបាលយុត្តិធម៌ ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីស៊ើបអង្កេតអាចប្រើប្រាស់សមត្ថកិច្ចជានគរបាលយុត្តិធម៌ ក្នុងការអនុវត្តសិទ្ធិនិងកាតព្វកិច្ចក្នុងការស៊ើបអង្កេតដូចមានចែងក្នុងប្រកាសនេះ និងដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងករណី ដូចខាងក្រោម៖

ក. គ្មានការសហការពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ដែលការមិនសហការនេះមិនមែនកើតចេញពីការមិនគោរពតាមកាតព្វកិច្ចរបស់មន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងប្រការ២២នៃប្រកាសនេះ ឬ

ខ. ការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ស្ថិតក្រោមមាត្រា៧នៃច្បាប់ស្តីពីការប្រកួតប្រជែង។

## ប្រការ១៤._ រយៈពេលនៃការបញ្ចប់ការស៊ើបអង្កេត

ការស៊ើបអង្កេតត្រូវបញ្ចប់ក្នុងរយៈពេលសមស្របណាមួយ តាមការសម្រេចរបស់ **គ.ប.ក.** តាមរយៈសំណើរបស់មន្ត្រីស៊ើបអង្កេត។ រយៈពេលកំណត់នៃការបញ្ចប់ការស៊ើបអង្កេតមិនរាប់បញ្ចូលរយៈពេលនៃការដោះស្រាយតាមការចរចា ដូចមានចែងក្នុងប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការដោះស្រាយតាមការចរចាឡើយ។

## ប្រការ១៥._ ការបញ្ចប់ការស៊ើបអង្កេត

នៅពេលបញ្ចប់ការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយមានភ្ជាប់ជាមួយភស្តុតាងនិងឯកសារពាក់ព័ន្ធផ្សេងៗ ជូនគណៈកម្មការលើករណីប្រកួតប្រជែង។ របាយការណ៍នេះត្រូវហៅថា **«របាយការណ៍ស្តីពីការស៊ើបអង្កេត»** ដែលទម្រង់នៃរបាយការណ៍នេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

ខ្លឹមសារសំខាន់ៗនៃរបាយការណ៍ស្តីពីការស៊ើបអង្កេតនេះ ត្រូវមានព័ត៌មានដូចខាងក្រោម៖

ក. ទិដ្ឋភាពទូទៅ៖ កាលបរិច្ឆេទបើកការស៊ើបអង្កេត ទីកន្លែងស៊ើបអង្កេត ទិដ្ឋភាពរួមនៃការប្រព្រឹត្តល្មើស សេចក្តីសង្ខេបអំពីការត្រួតពិនិត្យបឋម និងចម្លើយរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ

ខ. ប្រវត្តិនៃអង្គហេតុ៖ ការប្រព្រឹត្តទៅនៃនីតិវិធី

គ. ភស្តុតាងនៃការស៊ើបអង្កេត

ឃ. សេចក្តីសន្និដ្ឋាន និងការវាយតម្លៃលើភស្តុតាងនៃការស៊ើបអង្កេត និង

ង. សំណូមពរ។

បន្ទាប់ពីទទួលបានរបាយការណ៍ស្តីពីការស៊ើបអង្កេត គណៈកម្មការលើករណីប្រកួតប្រជែងត្រូវពិនិត្យនិងស្រាវជ្រាវលើករណីប្រកួតប្រជែង តាមរយៈការពិភាក្សា ការសាកសួរ និងការស្តាប់របាយការណ៍ស្តីពីការស៊ើបអង្កេត និងសេចក្តីបញ្ជាក់ការការពារខ្លួន ប្រសិនបើមាន ដោយត្រូវអនុវត្តនីតិវិធី ដូចមានចែងក្នុងប្រការ១០នៃប្រកាសនេះ ដើម្បីធ្វើសេចក្តីសន្និដ្ឋាន និងធ្វើរបាយការណ៍ជូន **គ.ប.ក.** ពិនិត្យ និងចេញសេចក្តីសម្រេច។

# ជំពូកទី៤
# សិទ្ធិ និងភារកិច្ចរបស់មន្ត្រីស៊ើបអង្កេត

## ប្រការ១៦._ សិទ្ធិបង្គាប់ឱ្យផ្តល់ឯកសារនិងព័ត៌មាន

នៅក្នុងកំឡុងពេលនៃការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដើម្បីបង្គាប់ឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត។ លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុននេះ ត្រូវហៅថា **«លិខិតជូនដំណឹងស្តីពីការបង្គាប់ឱ្យផ្តល់ឯកសារ និងព័ត៌មានពាក់ព័ន្ធ»** ដែលទម្រង់នៃលិខិតជូនដំណឹងស្តីពីការបង្គាប់ឱ្យផ្តល់ឯកសារ និងព័ត៌មានពាក់ព័ន្ធមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

លិខិតជូនដំណឹងស្តីពីការបង្គាប់ឱ្យផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធ ត្រូវកំណត់ឱ្យបានច្បាស់នូវព័ត៌មានដូចខាងក្រោម៖

ក. គោលបំណងនៃការបង្គាប់ឱ្យផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធ

ខ. សេចក្តីលម្អិតនៃឯកសារ និងព័ត៌មានពាក់ព័ន្ធដែលតម្រូវឱ្យផ្តល់ជូន

គ. កាលបរិច្ឆេទសម្រាប់ការផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធ ដែលមានរយៈពេលសមស្របណាមួយ តាមការកំណត់របស់មន្ត្រីស៊ើបអង្កេត

ឃ. ទម្រង់បែបបទនិងខ្លឹមសារនៃឯកសារនិងព័ត៌មានពាក់ព័ន្ធ ដែលតម្រូវឱ្យផ្តល់ជូន និង

ង. ប្រភេទនៃបទល្មើសនិងការពិន័យដែលត្រូវអនុវត្ត ក្នុងករណីដែលបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលពាក់ព័ន្ធមិនព្រមអនុវត្តតាម ឬមិនព្រមសហការជាមួយមន្ត្រីស៊ើបអង្កេត។

មន្ត្រីស៊ើបអង្កេត អាចថតចម្លង ឬដកស្រង់ឯកសារ និងខ្លឹមសារនៃឯកសារនិងព័ត៌មានពាក់ព័ន្ធនានា។

## ប្រការ១៧.- សិទ្ធិកោះហៅ

ក្នុងកំឡុងពេលនៃការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតមានសិទ្ធិកោះហៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលពាក់ព័ន្ធ ឱ្យចូលមកបង្ហាញខ្លួន ដើម្បីសាកសួរនិងប្រមូលយកព័ត៌មាននានា តាមរយៈការចេញលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ យ៉ាងតិចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនឱ្យចូលមកបង្ហាញខ្លួននេះត្រូវហៅថា «**លិខិតកោះហៅ**» ដែលទម្រង់នៃលិខិតកោះហៅមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

បន្ទាប់ពីការសាកសួរ មន្ត្រីស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុអំពីការសាកសួរ និងអានកំណត់ហេតុនេះឡើងវិញដោយសំឡេងខ្លាំងៗ ឱ្យបុគ្គលដែលផ្តល់ចម្លើយស្តាប់ ដោយអនុលោមតាមមាត្រា៩៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ កំណត់ហេតុនេះត្រូវហៅថា «**កំណត់ហេតុស្តាប់ចម្លើយ**» ដែលទម្រង់នៃកំណត់ហេតុស្តាប់ចម្លើយ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៦នៃប្រកាសនេះ។

កំណត់ហេតុស្តាប់ចម្លើយ ត្រូវកំណត់នូវព័ត៌មានដូចខាងក្រោម៖

ក. សេចក្តីបញ្ជាក់ការទទួលស្គាល់នូវភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយ

ខ. ហត្ថលេខា និង/ឬស្នាមមេដៃរបស់បុគ្គលដែលផ្តល់ចម្លើយនៅគ្រប់ទំព័រនីមួយៗនៃកំណត់ហេតុស្តាប់ចម្លើយ។ ប្រសិនបើបុគ្គលដែលផ្តល់ចម្លើយ មិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្នាមមេដៃទេ មន្ត្រីស៊ើបអង្កេតត្រូវចុះនិទ្ទេសអំពីការបដិសេធនេះ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ និង

គ. ហត្ថលេខា និង/ឬស្នាមមេដៃរបស់មន្ត្រីស៊ើបអង្កេត។

## ប្រការ១៨.- សិទ្ធិចូលទីកន្លែងផែកធេរដោយគ្មានដីកាអនុញ្ញាតឱ្យឆែកឆេរ

ក្នុងកំឡុងពេលនៃការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតមានសិទ្ធិចូលទៅក្នុងទីកន្លែងឆែកឆេររបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីបុគ្គលដែលកាន់កាប់ទីកន្លែងឆែកឆេរនោះ។

ការចូលទៅក្នុងទីកន្លែងឆែកឆេរត្រូវធ្វើឡើងចំពោះមុខសាក្សីយ៉ាងតិច ២(ពីរ)នាក់ ស្របតាមមាត្រា១១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយសាក្សីនោះមិនត្រូវជាមន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ។ សាក្សីមិនត្រូវជាបុគ្គលណាម្នាក់ដែលទទួលបានសិទ្ធិអំណាចក្នុងការស៊ើបអង្កេតដូចបានកំណត់ក្នុងប្រកាសនេះ។

ក្នុងកំឡុងពេលនៃការចូលទៅក្នុងទីកន្លែងឆែកឆេរ មន្ត្រីស៊ើបអង្កេតមានសិទ្ធិ៖

ក. រឹបអូសឬប្រមូលយកសម្ភារឬវត្ថុតាងនៅក្នុងទីកន្លែងឆែកឆេរ ដែលមានភាពចាំបាច់សម្រាប់ការស៊ើបអង្កេត ដោយអនុលោមតាមប្រការ២០នៃប្រកាសនេះ

ខ. បង្គាប់ឱ្យបុគ្គលណាម្នាក់នៅក្នុងទីកន្លែងឆែកឆេរ៖

- ផ្ដល់ និងរៀបចំឯកសារនិងព័ត៌មានពាក់ព័ន្ធ
- ផ្ដល់ការពន្យល់លើឯកសារនិងព័ត៌មានពាក់ព័ន្ធ
- បញ្ជាក់ឱ្យបានច្បាស់លាស់អំពីទីកន្លែងដែលអាចរកឃើញឯកសារនិងព័ត៌មានពាក់ព័ន្ធ
- បញ្ហាផ្សេងៗដែលមានភាពចាំបាច់ ឬពាក់ព័ន្ធនឹងការស៊ើបអង្កេត

គ. ថតចម្លង ឬដកស្រង់ឯកសារណាមួយ

ឃ. បង្គាប់ឱ្យថតចម្លងព័ត៌មាន ដែលមានភាពចាំបាច់និងពាក់ព័ន្ធនឹងការស៊ើបអង្កេត និង

ង. ការព្រមព្រៀងឬសកម្មភាពផ្សេងៗទៀតដែលមានភាពចាំបាច់និងពាក់ព័ន្ធនឹងការស៊ើបអង្កេត។

បន្ទាប់ពីបញ្ចប់ការឆែកឆេរដោយចូលក្នុងទីកន្លែងឆែកឆេរដោយគ្មានដីកាអនុញ្ញាតឱ្យឆែកឆេរ មន្ត្រីស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរស្ដីពីការឆែកឆេរ។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនេះ ត្រូវហៅថា «**កំណត់ហេតុឆែកឆេរ**» ដែលទម្រង់នៃកំណត់ហេតុឆែកឆេរមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៧នៃប្រកាសនេះ។

កំណត់ហេតុឆែកឆេរត្រូវបញ្ជាក់អំពី៖

ក. អត្តសញ្ញាណរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធដទៃទៀត បុគ្គលដែលជាម្ចាស់ ឬបុគ្គលកាន់កាប់ទីកន្លែងឆែកឆេរ និងសាក្សី ប្រសិនបើមាន

ខ. បញ្ជីសារពើភណ្ឌនៃវត្ថុតាងដែលបានចាប់យកឬប្រមូល ដូចមានចែងក្នុងប្រការ២០នៃប្រកាសនេះ និង

គ. ទំព័រនីមួយៗនៃកំណត់ហេតុឆែកឆេរ ត្រូវចុះហត្ថលេខា ឬផ្ដិតស្នាមមេដៃដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ។ ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្ដិតស្នាមមេដៃទេ មន្ត្រីស៊ើបអង្កេតត្រូវចុះនិទ្ទេសអំពីការបដិសេធនេះនៅក្នុងកំណត់ហេតុឆែកឆេរ។

## ប្រការ១៩._ សិទ្ធិចូលទីកន្លែងឆែកឆេរដោយមានដីកាអនុញ្ញាតឱ្យឆែកឆេរ

ក្នុងករណីគ្មានការយល់ព្រមពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ដែលកាន់កាប់ ឬជាម្ចាស់ទីកន្លែងឆែកឆេរឱ្យចូលទៅក្នុងទីកន្លែងឆែកឆេរ មន្ត្រីស៊ើបអង្កេតអាចប្រើប្រាស់សមត្ថកិច្ចរបស់ខ្លួនជានគរបាលយុត្តិធម៌ ដូចមានចែងក្នុងប្រការ១៣នៃប្រកាសនេះ ដើម្បីធ្វើការស្នើសុំដីកាអនុញ្ញាតឱ្យឆែកឆេរ តាមរយៈព្រះរាជអាជ្ញាពីប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី។

ការឆែកឆេរតាមរយៈការចូលទៅក្នុងទីកន្លែងឆែកឆេរ ដោយមានដីកាអនុញ្ញាតឱ្យឆែកឆេរត្រូវដឹកនាំដោយផ្ទាល់ពីព្រះរាជអាជ្ញា។

នីតិវិធី និងការធ្វើកំណត់ហេតុស្ដីពីការចូលទៅក្នុងទីកន្លែងឆែកឆេរ ដើម្បីធ្វើការឆែកឆេរដោយមានដីកាអនុញ្ញាតឱ្យឆែកឆេរ ត្រូវអនុលោមតាមមាត្រា១១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ប្រការ២០._ សិទ្ធិក្នុងការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីស៊ើបអង្កេតអាចចាប់យកឬប្រមូលវត្ថុតាង ដោយបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។

វត្ថុតាងដែលបានចាប់យកឬប្រមូល ត្រូវតែ៖

ក. បង្ហាញដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធដទៃទៀត បុគ្គលដែលជាម្ចាស់ ឬបុគ្គលកាន់កាប់ទីកន្លែងឆែកឆេរ និងសាក្សី និង

ខ. រាយនាមចូលក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុតាងដែលបានចាប់យកឬប្រមូល ដោយត្រូវចុះហត្ថលេខា និង/ឬផ្តិតស្នាមមេដៃដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលពាក់ព័ន្ធដទៃទៀត បុគ្គលដែលជាម្ចាស់ ឬបុគ្គលកាន់កាប់ទីកន្លែងឆែកឆេរ និងសាក្សី។ ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលពាក់ព័ន្ធមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្នាមមេដៃទេ មន្ត្រីស៊ើបអង្កេតត្រូវចុះនិទ្ទេសអំពីការបដិសេធនេះ នៅក្នុងកំណត់ហេតុឆែកឆេរ។

**ប្រការ២១.- សិទ្ធិស្នើសុំកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ច**

ប្រសិនបើការស៊ើបអង្កេតត្រូវស្ថិតក្រោមនិងពាក់ព័ន្ធនឹងវិស័យណាមួយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ចជាក់លាក់ណាមួយ មន្ត្រីស៊ើបអង្កេតមានសិទ្ធិស្នើសុំកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធនោះ តាមរយៈការស្នើសុំ និងការសម្រេចរបស់ **គ.ប.ក.**។

ផ្អែកតាមកិច្ចសហប្រតិបត្តិការនេះ **គ.ប.ក.** អាចស្នើសុំឱ្យក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធដូចខាងក្រោម៖

ក. ផ្តល់ឯកសារ និង/ឬព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត

ខ. សម្របសម្រួល និងផ្តល់កិច្ចសហប្រតិបត្តិការជាមួយ **គ.ប.ក.** ដើម្បីអនុវត្តមុខងាររៀងៗខ្លួន ដូចមានចែងក្នុងប្រកាសនេះ

គ. ចៀសវាងការបំពេញមុខងារជាន់គ្នាជាមួយ **គ.ប.ក.** និង

ឃ. ផ្តល់ការប្រឹក្សា និងពិគ្រោះយោបល់ដែលមានភាពចាំបាច់សម្រាប់ការស៊ើបអង្កេត។

ក្នុងគោលបំណងនៃកិច្ចសហប្រតិបត្តិការនិងការស៊ើបអង្កេត ក្រសួង ស្ថាប័ន ឬបញ្ញត្តិករមានសមត្ថកិច្ចដែលពាក់ព័ន្ធត្រូវមានកាតព្វកិច្ចដូចគ្នាជាមួយនឹងមន្ត្រីស៊ើបអង្កេតដូចមានចែងក្នុងប្រការ២៣នៃប្រកាសនេះ និងមាត្រា២២ និងមាត្រា២៣នៃច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ២២.- ភាតព្វកិច្ចរបស់មន្ត្រីស៊ើបអង្កេត**

ដើម្បីអនុវត្តសិទ្ធិនិងកាតព្វកិច្ច ក្នុងការស៊ើបអង្កេតដូចមានចែងក្នុងប្រការ១២នៃប្រកាសនេះ មុនពេលចាប់ផ្តើមការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវបង្ហាញនូវឯកសារនិងព័ត៌មានពាក់ព័ន្ធទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធដូចខាងក្រោម៖

ក. អត្តសញ្ញាណរបស់មន្ត្រីស៊ើបអង្កេត រួមមាន ឈ្មោះ ឋានៈ និងអង្គភាពបម្រើការងារ

ខ. លិខិតចាត់តាំងមន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងប្រការ១១នៃប្រកាសនេះ និង

គ. គោលបំណងនៃការស៊ើបអង្កេត និងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

ការខកខានមិនបានបំពេញកាតព្វកិច្ចរបស់មន្ត្រីស៊ើបអង្កេតដូចមានចែងក្នុងប្រការនេះ អនុញ្ញាតឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធអាចធ្វើការព្រងើយកន្តើយ ឬបដិសេធលើការសហការជាមួយមន្ត្រីស៊ើបអង្កេតបានដោយពុំមានការទទួលខុសត្រូវ ឬទទួលទោសទណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការប្រកួតប្រជែងនោះឡើយ។

## ប្រការ២៣.- ភាតព្វកិច្ចរក្សាការសម្ងាត់

មន្ត្រីស៊ើបអង្កេតមិនត្រូវលាតត្រដាងនូវរាល់ឯកសារ ឬព័ត៌មានដែលមានចរិកលក្ខណៈជាការសម្ងាត់ណាមួយ ដូចមានចែងក្នុងមាត្រា២២នៃច្បាប់ស្តីពីការប្រកួតប្រជែង លើកលែងតែមានហេតុផលណាមួយដូចមានចែងក្នុងមាត្រា២៣នៃច្បាប់ស្តីពីការប្រកួតប្រជែង។

## ប្រការ២៤.- ភាតព្វកិច្ចរក្សាទុកវត្ថុតាង

ដោយអនុលោមតាមប្រការ១២ ប្រការ១៨ ប្រការ១៩ និងប្រការ២០នៃប្រកាសនេះ មន្ត្រីស៊ើបអង្កេតត្រូវរក្សាទុកនូវវត្ថុតាងដែលប្រមូលបាន ដូចមានរៀបរាប់នៅក្នុងបញ្ជីសារពើភណ្ឌនៃវត្ថុតាងដែលបានចាប់យកដូចខាងក្រោម៖

ក. រក្សាទុកវត្ថុតាងនៅក្នុងកន្លែងបិទជិត

ខ. រក្សាទុកកំណត់ហេតុស្តីពីការចាប់យកឱ្យបានត្រឹមត្រូវ

គ. ធានាឱ្យបាននូវភាពត្រឹមត្រូវនៃការរក្សាទុក និង

ឃ. អនុវត្តសកម្មភាព និងវិធានការចាំបាច់នានា ដើម្បីគ្រប់គ្រងនិងរក្សាវត្ថុតាងឱ្យមានរបៀបរៀបរយ និងប្រកបដោយសុវត្ថិភាព។

## ប្រការ២៥.- ភាតព្វកិច្ចប្រគល់នូវវត្ថុតាងដែលបានចាប់យក

បន្ទាប់ពីការបញ្ចប់ការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវប្រគល់វត្ថុតាងដែលបានចាប់យកឬប្រមូលណាមួយ ឬទាំងអស់ជូនបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធណាមួយ ដែលវត្ថុតាងនោះត្រូវបានចាប់យក ឬប្រមូល ប្រសិនបើវត្ថុតាងទាំងនោះពុំមានប្រយោជន៍ ឬមិនពាក់ព័ន្ធនឹងបទល្មើស។

## ប្រការ២៦.- ការការពារផ្នែកច្បាប់របស់មន្ត្រីស៊ើបអង្កេត

មន្ត្រីស៊ើបអង្កេតត្រូវអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមនិងជំនួសឱ្យ **គ.ប.ក.** ដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសនេះ ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីស៊ើបអង្កេតមិនត្រូវទទួលខុសត្រូវក្នុងនាមបុគ្គលនូវរាល់សកម្មភាពដែលខ្លួនបានធ្វើ ឬត្រូវសន្មតថាបានធ្វើដោយភាពសុចរិត និងភាពស្មោះត្រង់ និងដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ នៅក្នុងកំឡុងពេលអនុវត្ត ឬត្រូវបានសន្មតថាបានអនុវត្តមុខងាររបស់ខ្លួនជាមន្ត្រីស៊ើបអង្កេត ឬអនុវត្តនូវសិទ្ធិនិងកាតព្វកិច្ចស្របច្បាប់ក្នុងការស៊ើបអង្កេតដូចមានចែងក្នុងប្រកាសនេះ ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រសិនបើមានបណ្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះសកម្មភាពរបស់មន្ត្រីស៊ើបអង្កេតដែលធ្វើឡើងដោយភាពសុចរិត ភាពស្មោះត្រង់ និងមានស្មារតីប្រុងប្រយ័ត្នខ្ពស់ **គ.ប.ក.** ត្រូវផ្តល់នូវជំនួយផ្នែកច្បាប់ដល់មន្ត្រីស៊ើបអង្កេតនោះ។

ការការពារផ្នែកច្បាប់ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើមន្ត្រីស៊ើបអង្កេតបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរនៅក្នុងកំឡុងពេលអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ដែលបានកំណត់ក្នុងប្រកាសនេះ ព្រមទាំងមានចែងក្នុងមាត្រា៦៤ និងមាត្រា៦៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

រាល់ការដាក់ពាក្យបណ្តឹងទៅលើការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់មន្ត្រីស៊ើបអង្កេតដែលបានកំណត់ក្នុងប្រការនេះ មិនប៉ះពាល់ឬជះឥទ្ធិពលទៅលើការកំណត់ ការវាយតម្លៃ និងដំណើរការនៃការស៊ើបអង្កេតដែលមានកំណត់ក្នុងប្រកាសនេះឡើយ។

## ជំពូកទី៥
## សិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត

### ប្រការ២៧.- សិទ្ធិក្នុងការការពារខ្លួន

បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធទទួលបានសិទ្ធិការពារខ្លួនស្របច្បាប់ តាមរយៈការធ្វើ និងដាក់ជូននូវសេចក្តីបញ្ជាក់ការការពារខ្លួន ដើម្បីឆ្លើយតបទៅនឹងសេចក្តីសំអាងហេតុ និងការសន្និដ្ឋានផ្សេងៗ ដែលធ្វើឡើងដោយមន្ត្រីស៊ើបអង្កេតនៅក្នុងរបាយការណ៍ស្តីពីការត្រួតពិនិត្យបឋម ដែលមានភ្ជាប់ជាមួយនឹង លិខិតជូនដំណឹងស្តីពីការចាប់ផ្តើមការស៊ើបអង្កេត ដូចមានចែងក្នុងប្រការ១១នៃប្រកាសនេះ និង/ឬស្ថិតក្នុង ដំណាក់កាលពិភាក្សា សាកសួរ និងស្តាប់របាយការណ៍ស្តីពីការស៊ើបអង្កេត ដូចមានចែងក្នុងប្រការ១៥នៃប្រកាសនេះ។ សេចក្តីបញ្ជាក់នេះត្រូវហៅថា «**សេចក្តីបញ្ជាក់ការការពារខ្លួន**»។

### ប្រការ២៨.- កាតព្វកិច្ចសហការ

បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តកាតព្វកិច្ចសហការជាមួយនឹងមន្ត្រីស៊ើបអង្កេត ដើម្បីអនុវត្តការស៊ើបអង្កេត ដូចមានចែងក្នុងប្រកាសនេះ។

កាតព្វកិច្ចសហការរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធមានដូចខាងក្រោម៖

ក. មិនត្រូវបំផ្លាញ ឬលាក់បំបាំងនូវរាល់ឯកសារ ព័ត៌មាន និង/ឬភស្តុតាង ដែលពាក់ព័ន្ធ ឬផ្នែកណាមួយ នៃការស៊ើបអង្កេត

ខ. មិនត្រូវបដិសេធក្នុងការឆ្លើយ ឬការចូលខ្លួនផ្តល់ចម្លើយតាមការស្នើសុំ និង/ឬ

គ. មិនត្រូវគេចវេះពីការអនុវត្តសកម្មភាពផ្សេងៗ ដែលតម្រូវដោយមន្ត្រីស៊ើបអង្កេត ដូចមានចែង ក្នុងប្រកាសនេះ។

### ប្រការ២៩.- ការទទួលខុសត្រូវរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ

រាល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ ដែលមិនអនុវត្តកាតព្វកិច្ចសហការជាមួយ មន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងប្រការ២៨នៃប្រកាសនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌស្របតាមក្រមព្រហ្មទណ្ឌ។

មន្ត្រីស៊ើបអង្កេតត្រូវធ្វើរបាយការណ៍ពាក់ព័ន្ធនឹងការមិនអនុវត្តកាតព្វកិច្ចសហការនោះ ដោយមានភ្ជាប់នូវ ឯកសារ ព័ត៌មាន និង/ឬភស្តុតាងពាក់ព័ន្ធទៅព្រះរាជអាជ្ញា។ ក្នុងករណីនេះ នីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៦
## កិច្ចសហប្រតិបត្តិការអន្តរជាតិ
## ក្នុងការស៊ើបអង្កេតលើករណីប្រកួតប្រជែង

### ប្រការ៣០.- កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការស៊ើបអង្កេតលើករណីប្រកួតប្រជែង

ផ្អែកលើមូលដ្ឋានកិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងអន្តរជាតិដែលមានជាធរមាន **គ.ប.ក.** អាចធ្វើ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធនឹងការប្រកួតប្រជែងនៃរដ្ឋបរទេស ចំពោះការស៊ើបអង្កេតលើ ការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងដែលកើតមានឡើងនៅក្នុង ឬក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។



N

ក្នុងករណីមានការស្នើសុំកិច្ចសហប្រតិបត្តិការពីស្ថាប័នពាក់ព័ន្ធនឹងការប្រកួតប្រជែងនៃរដ្ឋបរទេស ចំពោះការស៊ើបអង្កេតលើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងដែលបានកើតមានឡើងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែស្ថិតក្រោមវិសាលភាពច្បាប់ស្តីពីការប្រកួតប្រជែងនៃព្រះរាជាណាចក្រកម្ពុជា នីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេតចំពោះការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ត្រូវអនុវត្តដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងប្រកាសនេះ។

ប្រសិនបើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនោះ ត្រូវបានចាត់ទុកថាបានបំពានច្បាប់របស់រដ្ឋបរទេសណាមួយរួចហើយ នីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេតចំពោះសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ត្រូវអនុលោមតាមអនុស្សរណៈនៃការយោគយល់ និង/ឬកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេស ពាក់ព័ន្ធនឹងការប្រកួតប្រជែង ដោយរួមមានទាំងកិច្ចព្រមព្រៀងទ្វេភាគី និងថ្នាក់តំបន់។ ប្រសិនបើគ្មានអនុស្សរណៈនៃការយោគយល់ និង/ឬកិច្ចព្រមព្រៀងដៃគូសហប្រតិបត្តិការ ដើម្បីគ្រប់គ្រងកិច្ចសហប្រតិបត្តិការនៅក្នុងនីតិវិធីនៃការស៊ើបអង្កេតនោះទេ នីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេតត្រូវអនុវត្តដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

### ប្រការ៣១.- ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ៣២.- ការអនុវត្ត

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបសម្ព័ន្ធទី១**

សំណុំរឿងលេខ៖ ...............

# របាយការណ៍ស្តីពីការត្រួតពិនិត្យបឋម
## សូមគោរពជូន
## ឯកឧត្តមប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា

**កម្មវត្ថុ ៖** ស្តីពីការបញ្ជូនឯកសារគាំទ្រ និងភស្តុតាង នៅក្នុងសំណុំរឿង លេខ.............................................. ចុះថ្ងៃទី.................. ដែលមានបុគ្គលស្ថិតក្រោមការស៊ើបអង្កេតឈ្មោះ....................................។

**យោង ៖**

១. បទប្បញ្ញត្តិពាក់ព័ន្ធ

២. សំណុំរឿង លេខ..............ចុះថ្ងៃទី........ ខែ......... ឆ្នាំ............ របស់............................ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា** មេត្តាជ្រាបថា៖ មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «**ក.ប.ប.**»

**១. អង្គហេតុ**

..........................................................................................................................................

**២. ការបំពាន**

..........................................................................................................................................

**៣. សេចក្តីសង្ខេបអំពីលទ្ធផលត្រួតពិនិត្យបឋម**

..........................................................................................................................................

**៤. សេចក្តីសន្និដ្ឋាន**

..........................................................................................................................................

គួរបញ្ជាក់ផងដែរថា លទ្ធផលនៃការត្រួតពិនិត្យខាងលើ ត្រូវបានធ្វើឡើងដោយផ្អែកលើអង្គហេតុនិងការត្រួតពិនិត្យបឋម ដែលពាក់ព័ន្ធតែជាមួយនឹងករណីជាក់ស្តែងនៃការស៊ើបអង្កេតនេះតែប៉ុណ្ណោះ។

របាយការណ៍នេះមិនត្រូវចាត់ទុកជាវិធាន ដែលមានអានុភាពចាប់បង្ខំ នៅក្នុងតុលាការចំពោះរឿងក្តីផ្សេងៗទៀតនោះទេ។

ថ្ងៃ............................ ខែ.............. ឆ្នាំ........... ព.ស.២៥.......

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........ ឆ្នាំ២០.......

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ក.ប.ប.**

ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងលេខ៖ ................

# លិខិតជូនដំណឹង
# ស្តីពីការចាប់ផ្តើមការស៊ើបអង្កេត

**យោង៖**

១. សេចក្តីសម្រេចរបស់ **គ.ប.ក.** ចុះថ្ងៃទី...... ខែ......... ឆ្នាំ......... ស្តីពីការចាប់ផ្តើមការស៊ើបអង្កេត

២. លិខិតចាត់តាំងលើការបង្កើតគណៈកម្មការលើករណីប្រកួតប្រជែងលើសំណុំរឿង លេខ..........

៣. លិខិតចាត់តាំងមន្ត្រីស៊ើបអង្កេត លេខ ..................... ចុះថ្ងៃទី......... ខែ........... ឆ្នាំ ............

៤. របាយការណ៍ស្តីពីការត្រួតពិនិត្យបឋម ចុះថ្ងៃទី.......... ខែ......... ឆ្នាំ ..................

យើង...............................................ជាមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** សូមជម្រាបមក លោក/លោកស្រី..............................................ទីលំនៅបច្ចុប្បន្ន............................................................... ..................................................................................................................................................... ស្តីពីការចាប់ផ្តើមការស៊ើបអង្កេតនៅក្នុងករណី............................................................................................. លើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតឈ្មោះ.....................................ដែលតម្រូវឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ត្រូវបញ្ជូនសេចក្តីបញ្ជាក់ការការពារខ្លួនស្របច្បាប់មក អគ្គនាយកដ្ឋាន **ក.ប.ប.** ក្នុងរយៈពេល............................. ជាកំហិត គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះ។

ថ្ងៃ............................. ខែ............... ឆ្នាំ........... ព.ស.២៥.......

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........ ឆ្នាំ២០.......

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ក.ប.ប.**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបសម្ព័ន្ធទី៣**

សំណុំរឿងលេខ៖ ................

# របាយការណ៍ស្តីពីការស៊ើបអង្កេត

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវប្រធានគណៈកម្មការលើករណីប្រកួតប្រជែង**

**កម្មវត្ថុ ៖** ស្តីពីការបញ្ជូនភស្តុតាងនិងឯកសារពាក់ព័ន្ធ នៅក្នុងសំណុំរឿង លេខ............................................ ចុះថ្ងៃទី......................... ដែលមានបុគ្គលស្ថិតក្រោមការស៊ើបអង្កេតឈ្មោះ...............................។

**យោង ៖**

១. បទប្បញ្ញត្តិពាក់ព័ន្ធ....................................................................................................

២. សំណុំរឿង លេខ.................... ចុះថ្ងៃទី...... ខែ......... ឆ្នាំ............ របស់............................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ អគ្គនាយកដ្ឋាន **ក.ប.ប.** សូមគោរពរាយការណ៍ជូន **ឯកឧត្តម/លោកជំទាវប្រធានគណៈកម្មការលើករណីប្រកួតប្រជែង** មេត្តាជ្រាបថា៖

## ១. អង្គហេតុ

.......................................................................................................................................

## ២. ការបំពាន

.......................................................................................................................................

## ៣. សេចក្តីសង្ខេបអំពីលទ្ធផលនៃការស៊ើបអង្កេត

.......................................................................................................................................

## ៤. សេចក្តីសន្និដ្ឋាន

.......................................................................................................................................

គួរបញ្ជាក់ផងដែរថា លទ្ធផលនៃការស៊ើបអង្កេតខាងលើ ត្រូវបានធ្វើឡើងដោយផ្អែកលើអង្គហេតុនិងការស៊ើបអង្កេត ដែលពាក់ព័ន្ធតែជាមួយនឹងករណីជាក់ស្តែងនៃការស៊ើបអង្កេតនេះតែប៉ុណ្ណោះ។

របាយការណ៍នេះមិនត្រូវចាត់ទុកជាវិធាន ដែលមានអានុភាពចាប់បង្ខំ នៅក្នុងតុលាការចំពោះរឿងក្តីផ្សេងៗទៀតនោះទេ។

ថ្ងៃ............................ ខែ............... ឆ្នាំ........... ព.ស.២៥.......

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........ ឆ្នាំ២០.......

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ក.ប.ប.**

**ឧបសម្ព័ន្ធទី៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សំណុំរឿងលេខ៖** ...............

## លិខិតជូនដំណឹង
## ស្តីពីការបង្គាប់ឱ្យផ្តល់ឯកសារ និងព័ត៌មាន

**កម្មវត្ថុ ៖** ស្តីពីការបង្គាប់ឱ្យផ្តល់ឯកសារ ព័ត៌មាន និងកស្តុតាង នៅក្នុងសំណុំរឿង លេខ.......................... ចុះថ្ងៃទី........................ ដែលមានបុគ្គលស្ថិតក្រោមការស៊ើបអង្កេតឈ្មោះ..............................។

**យោង ៖**

១. លិខិតជូនដំណឹងស្តីពីការចាប់ផ្តើមការស៊ើបអង្កេត លេខ.......... ចុះថ្ងៃទី................................ របស់អគ្គនាយកដ្ឋាន **ក.ប.ប.**។

២. សំណុំរឿង លេខ................ ចុះថ្ងៃទី........ ខែ......... ឆ្នាំ............ របស់............................ ។

តបតាមកម្មវត្ថុ និងយោងខាងលើ យើង.....................................................ជាមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** បង្គាប់ឱ្យឈ្មោះ...............................ទីលំនៅបច្ចុប្បន្ន.................................................
...........................................................................................................................................
ផ្តល់ឯកសារ និងព័ត៌មាន ដូចខាងក្រោម៖

១. .........................................................................................................................................

២. .........................................................................................................................................

អាស្រ័យហេតុនេះ លោក/លោកស្រី ត្រូវផ្តល់ជូនមកយើងនូវឯកសារ ព័ត៌មាន និងកស្តុតាង ដូចបានរៀបរាប់ខាងលើ នៅក្នុងកំឡុងពេល..............ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងនេះ។

ប្រសិនបើ លោក/លោកស្រី មិនព្រមផ្តល់ជូន ឬមានការយឺតយ៉ាវក្នុងការផ្តល់ជូននូវឯកសារ ព័ត៌មាន និងកស្តុតាងទាំងនេះ ដោយពុំមានមូលហេតុសមស្រប ការពិន័យ និងទោសទណ្ឌ ដែលមានចែងនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងត្រូវយកមកអនុវត្ត។

ថ្ងៃ........................... ខែ.............. ឆ្នាំ.......... ព.ស.២៥......

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........ ឆ្នាំ២០......

**ហត្ថលេខា**

.....................................

មន្ត្រីស៊ើបអង្កេត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៥

សំណុំរឿងលេខ៖ ................

## លិខិតកោះហៅ

**យោង ៖**

១. លិខិតជូនដំណឹងស្តីពីការចាប់ផ្តើមការស៊ើបអង្កេត លេខ................. ចុះថ្ងៃទី........................... របស់ **គ.ប.ក.**

២. សំណុំរឿង លេខ................. ចុះថ្ងៃទី....... ខែ.......... ឆ្នាំ............ របស់.............................។

យើងជាមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** កោះហៅឈ្មោះ..................................... ទីលំនៅបច្ចុប្បន្ន................................................................................................................. ចូលមកបង្ហាញខ្លួននៅ................................ មានអាសយដ្ឋានស្ថិតនៅ............................................ ........................................................................................................................................... នៅថ្ងៃទី........ ខែ.......... ឆ្នាំ........... វេលាម៉ោង.......... និង........ នាទី ដើម្បី........................................ ..............................ករណី.......................................................................................................

*សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ៖

-.................................................................................................................................

-.................................................................................................................................

-.................................................................................................................................

ថ្ងៃ............................ ខែ.............. ឆ្នាំ........... ព.ស.២៥.......

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........ ឆ្នាំ២០.......

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ក.ប.ប.**

ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សំណុំរឿងលេខ៖** ...............

# កំណត់ហេតុស្តាប់ចម្លើយ

នៅអគ្គនាយកដ្ឋាន **ក.ប.ប.** ថ្ងៃទី........ ខែ.......... ឆ្នាំ.............. វេលាម៉ោង..................... និង........... នាទី យើង ............................................... ជាមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** អនុវត្តយ៉ាងត្រឹមត្រូវតាមលិខិតចាត់តាំង លេខ............................... ចុះថ្ងៃទី............................... ចេញដោយ............................... ដែលជំនួយដោយ..........................................................................................................

**ដោយមានសមាសភាពចូលរួម៖**

១/ ឈ្មោះ........................................ ភេទ......... តួនាទីជា.............................................................................

២/ ឈ្មោះ........................................ ភេទ......... តួនាទីជា ..........................................................................

កោះហៅឈ្មោះ.........................................................ទីលំនៅបច្ចុប្បន្ន .............................. ឱ្យចូលមកបង្ហាញខ្លួននៅចំពោះមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.**។ ចំពោះមុខមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** បុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានឆ្លើយដូចខាងក្រោម៖

**អំពីអត្តសញ្ញាណបុគ្គលស្ថិតក្រោមការស៊ើបអង្កេត៖**

- គោត្តនាមនិងនាម................................ភេទ..........ឈ្មោះជាអក្សរឡាតាំង..................................
  ឈ្មោះហៅក្រៅ..........................ជនជាតិ.......... សញ្ជាតិ.......... ថ្ងៃខែឆ្នាំកំណើត.........................
- ទីកន្លែងកំណើត...........................អាសយដ្ឋានបច្ចុប្បន្ន..................................................................
  ...........................................................................................................................
- អត្តសញ្ញាណបណ្ណលេខ.............................. ចុះថ្ងៃទី....................... ផ្តល់នៅ............................
- លិខិតឆ្លងដែនលេខ.............................. ចុះថ្ងៃទី....................... ផ្តល់នៅ............................
- មុខរបរ/ការងារ.......................................................... ទូរស័ព្ទលេខ.......................................
- ប្រវត្តិសកម្មភាព..........................................................................................................

**ចំពោះមុខមានអ្នកបកប្រែ**................................................................................... (សម្រាប់ជនបរទេស)

- គោត្តនាមនិងនាម.......................................... ភេទ......... ជនជាតិ............ សញ្ជាតិ.............
- ថ្ងៃខែឆ្នាំកំណើត................................ទីកន្លែងកំណើត.......................................................
- អាសយដ្ឋានបច្ចុប្បន្ន...................................................................................................
- អត្តសញ្ញាណបណ្ណលេខ.......................... ចុះថ្ងៃទី...................... ផ្តល់នៅ ...........................
- លិខិតឆ្លងដែនលេខ.......................... ចុះថ្ងៃទី...................... ផ្តល់នៅ ...........................
- មុខរបរ/ការងារ............................កំរិតវប្បធម៌....................... ទូរស័ព្ទលេខ ..........................

## សំណួរនិងចម្លើយ

..................................................................................................................................................................

..................................................................................................................................................................

កំណត់ហេតុនេះបានធ្វើចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែលវេលាម៉ោង......... និង..........នាទី និងបានអានសារឡើងវិញដោយមន្ត្រីស៊ើបអង្កេតជូនបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងអ្នកចូលរួម។

បុគ្គលស្ថិតក្រោមការស៊ើបអង្កេត អ្នកចូលរួម និងសាក្សី បានអាននិងបានបញ្ជាក់អះអាងថា ពិតជាត្រឹមត្រូវ និងយល់ព្រមផ្តិតស្នាមមេដៃ ឬចុះហត្ថលេខា ដូចខាងក្រោមៈ

| **អ្នកចូលរួម** | **ជំនួយការ** | **មន្ត្រីស៊ើបអង្កេត** |
|---|---|---|
| ១/................................. | | |
| ២/................................. | | |
| ៣/.................................. | ............................. | ........................................ |
| ៤/................................. | | |
| ៥/................................. | **ស្នាមមេដៃ** | |
| ៦/.................................. | **បុគ្គលស្ថិតក្រោមការស៊ើបអង្កេត** | **អ្នកបកប្រែ** |
| ៧/................................. | | |
| | .......................................... | .............................. |

ឧបសម្ព័ន្ធទី៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងលេខ៖ ................

## កំណត់ហេតុឆែកឆេរ

**យោង ៖**

១. លិខិតជូនដំណឹងស្តីពីការចាប់ផ្តើមការស៊ើបអង្កេត លេខ៖.......... ចុះថ្ងៃទី...... ខែ....... ឆ្នាំ......... របស់អគ្គនាយកដ្ឋាន **ក.ប.ប.**។

២. សំណុំរឿង លេខ........... ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់............................. ។

**កាលបរិច្ឆេទចុះឆែកឆេរ៖** ថ្ងៃទី........... ខែ.......... ឆ្នាំ.............. វេលាម៉ោង..............និង............... នាទី យើង............................................................... ជាមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** អនុវត្តយ៉ាងត្រឹមត្រូវតាមសេចក្តីសម្រេចលេខ...................ចុះថ្ងៃទី..........................ចេញដោយ.......................... ដែលជំនួយដោយ.............................................................................................................

**ចូលរួមដោយ៖**

១/ ឈ្មោះ.................................... ភេទ......... តួនាទីជា..........................................................
២/ ឈ្មោះ.................................... ភេទ......... តួនាទីជា..........................................................
៣/ ឈ្មោះ.................................... ភេទ......... តួនាទីជា..........................................................
៤/ ឈ្មោះ.................................... ភេទ......... តួនាទីជា..........................................................
៥/ ឈ្មោះ.................................... ភេទ......... តួនាទីជា..........................................................

បានធ្វើការត្រួតពិនិត្យ.........................................................................ផ្ទះលេខ........ ផ្លូវ............... ក្រុម.......... ភូមិ................ សង្កាត់/ឃុំ...............ក្រុង/ខណ្ឌ/ស្រុក.................. រាជធានី/ខេត្ត.................. យើងធ្វើការឆែកឆេរ.................................... នៅចំពោះមុខ..............................................។

នៅក្នុងកំឡុងពេលនៃការឆែកឆេរ និងការត្រួតពិនិត្យនេះ យើងបានរកឃើញ និងចាប់យកសម្ភារ វត្ថុតាង រួមមាន៖

| **ល.រ** | **ឈ្មោះវត្ថុតាង** | **សេចក្តីលម្អិត** (បរិមាណ គុណភាព ផ្សេងៗ) | **ចំនួន** |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

វត្ថុតាងដែលឆែកឆេរកឃើញខាងលើ យើងបានសម្រេចចាប់យកជាបណ្តោះអាសន្ន ហើយបានប្រគល់ទៅឱ្យ....................................... ដើម្បីរក្សាទុក។ ក្រៅពីសម្ភារ និងវត្ថុតាងខាងលើនេះ យើងខ្ញុំពុំបានចាប់យកសម្ភារអ្វីផ្សេង ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិម្ចាស់ទីកន្លែងឆែកឆេរឡើយ។

កំណត់ហេតុនេះបានធ្វើចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែលវេលាម៉ោង..........និង...........នាទី និងបានអានសារឡើងវិញដោយមន្ត្រីស៊ើបអង្កេត ជូនបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងអ្នកចូលរួម។

បុគ្គលស្ថិតក្រោមការស៊ើបអង្កេត អ្នកចូលរួម និងសាក្សី បានអាន និងបានបញ្ជាក់អះអាងថាពិតជាត្រឹមត្រូវ និងយល់ព្រមផ្តិតស្នាមមេដៃ ដូចខាងក្រោម។

| **អ្នកចូលរួម** | **ជំនួយការ** | **មន្ត្រីស៊ើបអង្កេត** |
|---|---|---|
| ១/.................................. | | |
| ២/.................................. | | |
| ៣/.................................. | ............................. | ....................................... |
| ៤/.................................. | | |
| ៥/.................................. | | |
| ៦/.................................. | | |
| ៧/.................................. | | |

**ស្នាមមេដៃ**

| **បុគ្គលស្ថិតក្រោមការស៊ើបអង្កេត** | **សាក្សី** |
|---|---|
| .............................................. | ............................... |